ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងដំណាំ ស្វាយកែវរមៀត
## (ដោយមិនប្រើថ្នាំគីមីជម្រុញផល)



គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃ អេ.អ.ឌី.ប៊ី , ខែមេសា ឆ្នាំ២០២២

# ដំណាំស្វាយកែវរមៀត

ដំណាំឈើហូបផ្លែស្វាយកែវរមៀត គឺជាដំណាំកសិ-ឧស្សាហកម្មដែលមានសក្តានុពលសម្រាប់បម្រើដល់ទីផ្សារក្នុងស្រុក និងការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ ជាពិសេសទៅកាន់ប្រទេសចិន និងសាធារណៈរដ្ឋកូរ៉េ ដោយនាំចេញជាលក្ខណៈផ្លែស្វាយស្រស់ និងក្រៀម។

ស្វាយកែវរមៀតត្រូវបានដាំដុះនៅតំបន់ដែលមានអាកាសធាតុត្រូពិច និងតំបន់ក្តៅមធ្យម។

## ១. ផ្ទៃដីដាំដុះ និងបរិមាណផលដំណាំស្វាយ

តាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នៅទូទាំងប្រទេសដំណាំស្វាយដាំដុះបាន ÷

| ល.រ | លក្ខណៈដាំដុះ | ផ្ទៃដីដាំដុះសរុប (ហិកតា) | ផ្ទៃដីដាំដុះទទួលផលសរុប(ហិកតា) | ទិន្នផលជាមធ្យម (តោន/ហិកតា) | បរិមាណផលសរុប (តោន) |
|---|---|---|---|---|---|
| ១ | លក្ខណៈគ្រួសារ | 134,529 | 96,990 | 15.31 | 1,485,332 |
| ២ | លក្ខណៈក្រុមហ៊ុន | 3,421 | 210 | 50,67 | 10,657 |
| **I** | **សរុប ឆ្នាំ ២០២០** | **137,950** | **97,200** | **15,40** | **1,495,989** |
| **II** | **សរុប ឆ្នាំ ២០២១** | **152,073** | **108,044** | **20.34** | **2,197,266** |

### ផលិតកម្មដំណាំស្វាយ ឆ្នាំ២០២១

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីដាំដុះ (ហិកតា) | ផ្ទៃដីប្រមូលផល (ហិកតា) | ទិន្នផល (តោន/ហិកតា) | បរិមាណផល (តោន) |
|---|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | 1,794 | 1,325 | 15.082 | 19,983 |
| 2 | បាត់ដំបង | 17,184 | 10,793 | 25.369 | 273,807 |
| 3 | កំពង់ចាម | 3,940 | 3,646 | 18.662 | 68,042 |
| 4 | កំពង់ឆ្នាំង | 10,320 | 8,072 | 24.513 | 197,868 |
| 5 | កំពង់ស្ពឺ | 34,733 | 30,610 | 26.494 | 810,990 |
| 6 | កំពង់ធំ | 8,771 | 4,074 | 24.799 | 101,031 |
| 7 | កំពត | 8,633 | 7,541 | 9.000 | 67,869 |
| 8 | កណ្តាល | 8,285 | 6,430 | 8.000 | 51,440 |
| 9 | កោះកុង | 208 | 208 | 4.000 | 832 |
| 10 | ក្រចេះ | 813 | 653 | 12.202 | 7,968 |

| | | | | | |
|---|---|---|---|---|---|
| 11 | មណ្ឌលគិរី | 951 | 845 | 13.184 | 11,141 |
| 12 | ភ្នំពេញ | - | - | | - |
| 13 | ព្រះវិហារ | 1,402 | 963 | 15.000 | 14,445 |
| 14 | ព្រៃវែង | 1,468 | 1,260 | 23.749 | 29,926 |
| 15 | ពោធិ៍សាត់ | 2,712 | 2,010 | 20.500 | 41,205 |
| 16 | រតនគិរី | 4,584 | 4,584 | 5.668 | 25,980 |
| 17 | សៀមរាប | 2,580 | 2,580 | 7.000 | 18,060 |
| 18 | ព្រះសីហនុ | 10,589 | 1,218 | 12.200 | 14,859 |
| 19 | ស្ទឹងត្រែង | 3,701 | 3,701 | 8.000 | 29,608 |
| 20 | ស្វាយរៀង | 998 | 674 | 36.620 | 24,682 |
| 21 | តាកែវ | 5,269 | 2,600 | 30.000 | 78,000 |
| 22 | ឧត្តរមានជ័យ | 13,515 | 5,717 | 27.701 | 158,368 |
| 23 | កែប | 1,036 | 1,030 | 18.997 | 19,567 |
| 24 | ប៉ៃលិន | 5,862 | 5,510 | 16.879 | 93,005 |
| 25 | ត្បូងឃ្មុំ | 2,725 | 2,000 | 19.295 | 38,590 |
| **សរុប** | | **152,073** | **108,044** | **20.337** | **2,197,266** |

ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

## ២. ការនាំចេញផ្លែស្វាយស្រស់

តាមរបាយការណ៍របស់ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទក្នុងឆ្នាំ២០២០កន្លងទៅ ការនាំចេញផ្លែស្វាយស្រស់ទៅកាន់ទីផ្សារក្រៅប្រទេសមានចំនួន ៩៥៧,៦៨០តោន ក្នុងនោះចំនួន ១០៧,៦៨០តោន បាននាំចេញដោយមានវិញ្ញាបនបត្រភូតគាមអនាម័យ និងចំនួន៨៥០,០០០តោនទៀតត្រូវបាននាំចេញដោយគ្មានវិញ្ញាបនបត្រភូតគាមអនាម័យ។ នៅក្នុងឆ្នាំ ២០២១ វិញការនាំចេញផ្លែស្វាយស្រស់បានប្រមាណជាង ២៤ម៉ឺនតោនទៅកាន់ទីផ្សារសំខាន់ៗដូចជា វៀតណាម ថៃ ចិន កូរ៉េខាងត្បូង ជាដើម។

## ៣.ការដាំដុះ និងរដូវកាល

### ៣-១)-ទីកន្លែងដាំដុះ

-ស្វាយកែវរមៀតជាប្រភេទដំណាំងាយដាំស៊ាំនឹងតំបន់ដីស្ងួត ដីខ្សោះជីវជាតិជាដើម គេអាចដាំបាននៅលើដីច្រើនប្រភេទប៉ុន្តែសមស្របបំផុតគឺលើដីជិតប្រភពទឹក ដីមិនដក់ទឹក និងដីទួលជម្រាល។ កសិករនិយមដាំដុះដើមប៉ិរនៅដើមរដូវវស្សាចាប់ពីខែឧសភា ដល់ខែ មិថុនា។

**៣-២)-ការរៀបចំដី និងរណ្ដៅ**

-ត្រូវពង្រាបដីឱ្យរាបស្មើ (ដីកប្រព័ន្ធរំដោះទឹក) បើតំបន់ដីទំនាបត្រូវលើករង ឬពូនគល់ឱ្យខ្ពស់។

-ចាប់ផ្ដើមកាប់រណ្ដៅដាំនៅដើមរដូវភ្លៀងក្នុងកំឡុងខែឧសភា-មិថុនា។

-រណ្ដៅមានទំហំ១ម៉ែត្របួនជ្រុងនិងជម្រៅកន្លះម៉ែត្រ។នៅបាតរណ្ដៅនីមួយៗត្រូវដាក់ស្លឹកឈើស្រស់ដូចជាទន្ទ្រានខែត្រជាន់ឱ្យណែនកម្រាស់៣តឹក លាមកគោស្ងួត២តឹក ដី១តឹកនៅខាងលើបង្អស់ ។ ក្រោយពីដាក់ជីហើយទុកចោលរយៈពេល១អាទិត្យដើម្បីឱ្យស្លឹកទន្ទ្រានខែត្ររលួយ បន្ទាប់មកជ្រុំជ្រោយដីក្នុងរណ្ដៅឱ្យសព្វទើបដាក់កូនស្វាយដាំ ។

**៣-៣)-ការដាំ ÷**

-កូនស្វាយដែលបណ្ដុះទុកមានអាយុពី ៦ខែ ទៅ៧ខែ

-យកកូនស្វាយទៅកប់ដាំក្នុងរណ្ដៅដែលបានត្រៀមទុក

-ការដាំដើមស្វាយអាចដាំបានពីចន្លោះគុម្ពនីមួយៗ ពី ៥ម x ៥ម ឬរហូតដល់ ៨ម ឬ ៨ម




-ក្រោយពីដាំហើយ ស្រោចទឹកឱ្យជោក បន្ទាប់មកយកកម្ទេចកម្ទីស្លឹកឈើស្ងួតគ្របគល់ស្វាយ ដើម្បីកុំឱ្យហួតសំណើម ។

-សម្អាតស្មៅនៅជុំវិញគល់ឱ្យបានទៀងទាត់

-ដោតឈើជន្លង់ចងផ្ដោបនិងកូនដើម និងការពារកំដៅថ្ងៃខ្លាំង

-រៀបចំប្រព័ន្ធទឹកស្រោចស្រពដំណាំឱ្យបានគ្រប់គ្រាន់

**៣-៤)-ការថែទាំ ÷**

-ក្រោយពីដាំហើយត្រូវចាប់ផ្ដើមស្រោចទឹកមួយដងក្នុងមួយថ្ងៃ រហូតដល់ស្វាយលាស់ត្រួយថ្មី ទើបបន្ថយការស្រោចទឹកមកនៅត្រឹមមួយអាទិត្យម្ដង ។

-នៅពេលស្វាយអាយុបាន១-២ឆ្នាំ ត្រូវជីកចង្អូរជារង្វង់នៅជុំវិញដើមចម្ងាយពីដើមប្រហែលមួយម៉ែត្រទៅមួយម៉ែត្រកន្លះ។ជម្រៅចង្អូរ២តឹករួចដាក់ស្លឹកឈើស្រស់និងលាមកគោក្នុងចង្អូររួចលុបដី និងស្រោចទឹក ។ ក្រៅពីការដាក់ជីស្រោចទឹក ត្រូវជម្រះស្មៅនៅក្បែរគល់និងនៅចន្លោះរង ។

-ការបន្ថែមជីត្រូវធ្វើឡើងរៀងរាល់ឆ្នាំ ហើយជីកចង្អូរនៅជុំវិញដើម និងដាក់ជីនៅក្នុងចង្អូរនោះ ។

### ៣-៥)-ការប្រើប្រាស់ជី

-ដាក់ជីលាមកសត្វទ្រាប់បាត ចំនួន ១៥ ទៅ ២០គីឡូក្រាម និងដាក់បន្ថែមមេតំបែរជីវសាស្ត្រប៉ូតាស្យូម ០,៥គក្រ និងរោយកំបោរពី ០,៣ ទៅ ០,៥គក្រ/រណ្តៅ។

### ៣-៦)-ការស្រោចទឹក និងផ្អាប់គល់

-ដើមស្វាយត្រូវការទឹកក្នុងបរិមាណសមល្មម។ គេអាចស្រោចទឹកយ៉ាងតិចមួយដង/សប្តាហ៍នៅពេលកូនស្វាយអាយុតិចជាង ២ឆ្នាំ ជាពិសេសនៅរដូវប្រាំងដោយមិនចាំបាច់ស្រោចទឹកជោគជាំនោះទេ។

### ៣-៧)-ការតាក់តែងមែក

-ក្រោយពេលដាំរយៈពេលចាប់ពី ១ដល់ ៣ឆ្នាំត្រូវធ្វើការតាក់តែងមែកជាប្រចាំ

-កាត់មែកដែលមិនល្អចេញ (មែកដុះទេរខ្លាំង មែកលូតលាស់មិនល្អ មែកគងលើគ្នា..)

-ក្រោយពេលកាត់មែកចេញហើយត្រូវយកកំបោរលាបស្នាមកាត់ដើម្បីការពារមេរោគឆ្លង

-ក្រោយពេលតាក់តែងមែកហើយត្រូវធ្វើស្មៅឱ្យបានស្អាតល្អនិងគប្បីដាក់ជីភ្លាមៗ (ជី 15-15-15 ក្នុងកម្រិត 2-3 គីឡូក្រាម/ដើម) និងយករុក្ខជាតិផ្អាប់គល់ស្វាយ។

## ៤)-ការប្រមូលផល តម្លៃ និងទីផ្សារលក់ផលិតផលផ្លែស្វាយ

### ៤-១)-ការប្រមូលផល

-ស្វាយអាចចាប់ផ្តើមឱ្យផលលើកដំបូង ពីអាយុ៣ ទៅ៤ឆ្នាំឡើងទៅបន្ទាប់ពីដាំ និងអាចបន្តផ្តល់ផលបានរហូតដល់ ២០ ទៅ ២៥ឆ្នាំ

-ស្វាយជាទូទៅអាចប្រមូលផលតាមពូជស្វាយក្នុងចន្លោះពី ១១០ ទៅ ១២០ថ្ងៃ គិតពីពេលចេញផ្កា។

-ទិន្នផលចាប់ផ្តើមដំបូងពី ២០ ទៅ ៣០គក្រ/ដើម (ដើមស្វាយអាយុ ៤ឆ្នាំឡើងទៅ) ដោយសារគេត្រូវកាត់ជម្រុះក្តិបចោលខ្លះដើម្បីកុំឱ្យបាក់មែក។

-ឆ្នាំបន្តបន្ទាប់បានកើនចាប់ពី ៥០ គក្រ/ដើម ដល់១២០ គក្រ/ដើម ករណីមានការថែទាំដិតដល់ល្អ។

**៤-២)-ទីផ្សារលក់ផលិតផល និងតម្លៃ**

ជុំវិញបញ្ហានេះក្រុមកសិករប្រកបរបរដាំស្វាយកែវរមៀតមួយចំនួនបានគូសបញ្ជាក់ថា បញ្ហាទីផ្សារនៅតែជាឧបសគ្គសម្រាប់ពួកគាត់ពិសេសអំឡុងវិបត្តិកូវីដ១៩តែម្តង ហើយរហូតមកដល់ពេលនេះបញ្ហាទីផ្សារនៅតែបន្តកើតមានសម្រាប់អ្នកដាំស្វាយ។

ក្រុមកសិករដាំស្វាយកែវរមៀតមួយចំនួនបានគូសបញ្ជាក់ថា ដ្បិតបច្ចុប្បន្នក្រុមកសិករបានចងក្រងជាបណ្តុំសហគមន៍ និងកែសម្រួលបច្ចេកទេសដាំដុះក៏ពិតមែន តែមិនទាន់អាចដោះស្រាយបញ្ហាទីផ្សារបាននៅឡើយព្រោះក្រុមកសិករនៅតែពឹងផ្អែកលើឈ្មួញកណ្តាល ពិសេសមិនទាន់មានទំនាក់ទំនងជាមួយក្រុមហ៊ុននាំចេញស្វាយទៅទីផ្សារអន្តរជាតិដែលធ្វើឱ្យក្រុមកសិករមិនទាន់យល់ច្បាស់ពីលក្ខខណ្ឌតម្រូវសម្រាប់នាំចេញផ្លែស្វាយដែលអាចនាំចេញទៅទីផ្សារអន្តរជាតិបាន (ដូចជាមិនត្រូវមានសំណល់ថ្នាំកសិកម្ម និងសមាសភាពចម្រៃ ដែលនៅក្នុងផ្លែស្វាយនោះ ពិសេសចាប់ពីការដាំដុះរហូតដល់ការធ្វើប្រព្រឹត្តកម្មស្វាយ ។ល។)។

តម្លៃលក់ផ្លែស្វាយចេញពីចំការមួយរយៈចុងក្រោយនេះបានធ្លាក់ថ្លៃដល់ ១៥០៛ ទៅ ១៨០៛/គក្រ។

| ប្រភេទផ្លែស្វាយ | តម្លៃផ្លែស្វាយ (រៀល/ គីឡូក្រាម) | | | | |
|---|---|---|---|---|---|
| | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** | **ឆ្នាំ ២០២១** | **ដើមឆ្នាំ២០២២** | |
| ស្វាយខៀវ | 800-1,200 | 600-800 | 600-800 | 400-500 | បញ្ចាឱ្យផ្លែ ប្រមូលផលនៅក្នុងខែ តុលា វិច្ឆិកា ធ្នូ |
| ស្វាយខ្ចប់ | 1,500-1,700 | 1,000-1,200 | 1,000-1,200 | 700-800 | |
| ស្វាយខៀវ | 200-300 | 200-300 | 200-300 | 150-180 | ផ្លែតាមរដូវ ប្រមូលផលនៅខែមេសា |

**៥.ទិន្នផល÷** ទិន្នផលមានការកើនឡើងជារៀងរាល់ឆ្នាំ ក្នុង១ដើមគឺអាចទទួលផលនៅឆ្នាំដំបូងបានចន្លោះពី ២០ ទៅ៣០គីឡូក្រាម និងអាចកើនឡើងដល់រាប់រយគីឡូក្រាមអាស្រ័យលើអាយុកាលនៃដើម។

## ៦.ចំណូល ចំណាយ ដាំនិងថែទាំដើមស្វាយកែវរមៀតចំនួន ២០៥ដើម/ហិចតា

(គម្លាតពីគុម្ពមួយទៅគុម្ពមួយ ៧ម៉ែត្រ)

| | បរិយាយ | ឯកតា | បរិមាណ | ថ្លៃឯកតា (រៀល) | ចំណាយសរុប (រៀល) | ចំនួនរំលស់ | ចំណាយបូកនិងរំលស់/ឆ្នាំជារៀល |
|---|---|---|---|---|---|---|---|
| I | **-ចំណាយលើការចាប់ផ្តើម** | | | | **12,955,600** | | **6,043,600** |
| | **ក-ចំណាយប្រែប្រួល** | | | | **4,515,600** | | **4,515,600** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 1 | ការសំអាតដី | ha | 1 | 130,000 | 130,000 | 1 | 130,000 |
| 2 | ភ្ជួរដីចំការ | ha | 1 | 120,000 | 120,000 | 1 | 120,000 |
| 3 | បោះបង្គោលតម្រង់ជួរស្វាយ | ha | 1 | 80,000 | 80,000 | 1 | 80,000 |
| 4 | ឈ្នួលជីករណ្ដៅ(1mx1mx0.5m) | រណ្ដៅ | 205 | 8,000 | 1,640,000 | 1 | 1,640,000 |
| 5 | ឈ្នួលដាំកូនស្វាយ | ដើម | 205 | 500 | 102,500 | 1 | 102,500 |
| 6 | ពូជ (ថ្លៃកូនស្វាយ) | ដើម | 205 | 5,000 | 1,025,000 | 1 | 1,025,000 |
| 7 | ថ្លៃដឹកជញ្ជូនពូជកូនស្វាយ | ដើម | 205 | 320 | 65,600 | 1 | 65,600 |
| 8 | ជីធម្មជាតិ១០គក្រ/រណ្ដៅ x ២០៥ | គក្រ | 1,050 | 500 | 525,000 | 1 | 525,000 |
| 9 | កំបោរស ០.៥គក្រ/រណ្ដៅ | គក្រ | 103 | 2,700 | 278,100 | 1 | 278,100 |
| 10 | ឈ្នួលដាក់ជី | គុម្ព | 205 | 500 | 102,500 | 1 | 102,500 |
| 11 | ថ្នាំសម្លាប់សត្វកណ្ដៀរដោយប្រើ ១គក្រ/រណ្ដៅ | គក្រ | 205 | 2,000 | 410,000 | 1 | 410,000 |
| 12 | ឈើជន្ទល់ និងរបាំងការពារ | ដើម | 205 | 180 | 36,900 | 1 | 36,900 |
| | **ខ-ចំណាយមិនប្រែប្រួល** | | | | **8,440,000** | | **1,528,000** |
| 8 | ប្រព័ន្ធទុយោទឹក | សំណុំ | 1 | 1,600,000 | 1,600,000 | 5 | 320,000 |
| 9 | ជីកស្រះ/អាងស្តុកទឹក | អាង | 1 | 2,800,000 | 2,800,000 | 10 | 280,000 |
| 10 | ម៉ាស៊ីនបូមទឹក | គ្រឿង | 1 | 3,280,000 | 3,280,000 | 5 | 656,000 |
| 11 | ធុងបាញ់ថ្នាំ | គ្រឿង | 1 | 400,000 | 400,000 | 2 | 200,000 |
| 12 | ម៉ាស៊ីនកាត់ស្មៅ | គ្រឿង | 1 | 360,000 | 360,000 | 5 | 72,000 |
| **II** | **-ចំណាយលើការថែទាំឆ្នាំទី ១** | | | | **5,329,000** | | **5,329,000** |
| 1 | បាញ់ថ្នាំសម្លាប់សត្វល្អិត ៣ខែម្តង | | 4 | 100,000 | 400,000 | | 400,000 |
| 2 | ដាក់ជីលាមកសត្វ២ដង/ឆ្នាំ | ការ៉ុង | 410 | 3,000 | 1,230,000 | | 1,230,000 |
| 3 | ពលកម្មថែទាំ ដាក់ជី តែងមែក | នាក់ដង | 205 | 5,000 | 1,025,000 | | 1,025,000 |
| 4 | ពលកម្មកាត់ស្មៅ | នាក់ដង | 12 | 40,000 | 480,000 | | 480,000 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 5 | ប្រេងកាត់ស្មៅ ៥លីត្រ/ថ្ងៃ | លីត្រ | 60 | 4,100 | 246,000 | | 246,000 |
| 6 | ប្រេងម៉ាស៊ូតបូមទឹកស្រោច | លីត្រ | 120 | 3,500 | 420,000 | | 420,000 |
| 7 | ចំណាយកាត់រំលស់ប្រចាំឆ្នាំ | | | | 1,528,000 | | 1,528,000 |
| III | **សរុបចំណាយក្នុងឆ្នាំទី១** (I+II) | | | | **18,284,600** | | **11,372,600** |
| IV | **-ចំណាយលើការថែទាំឆ្នាំទី ២** | | | | **5,329,000** | | **5,329,000** |
| V | **-ចំណាយលើការថែទាំឆ្នាំទី ៣** | | | | **5,329,000** | | **5,329,000** |
| VI | **-ចំណាយដំណាំស្វាយសរុប៣ឆ្នាំដំបូង** (III+IV+V) | | | | **28,942,600** | | **22,030,600** |
| VII | **-ចំណាយថែទាំដំណាំស្វាយឆ្នាំទី៤ និងផលចំណូលលើកដំបូង** | | | | **5,329,000** | | **5,329,000** |
| 1 | ចំណាយប្រចាំឆ្នាំ | | | | 5,329,000 | | 5,329,000 |
| 2 | ចំណាយលើកម្មករប្រមូលផល | | | | | | |
| 3 | ចំណាយដឹកជញ្ជូន | | | | | | |
| VIII | **៨)-ផលចំណូលពីការលក់ផ្លែស្វាយលើកដំបូង** | | | | **4,428,000** | | **4,428,000** |
| | ទិន្នផលប្រចាំឆ្នាំ 30kg x 205 ដ =6,150 kg កាត់ចេញ 10 % នៅសល់ 5,535 kg | | 5,535 | 800 | 4,428,000 | | 4,428,000 |

**សំគាល់**÷ ករណីការកំណត់កំណើនទិន្នផលសុទ្ធប្រចាំឆ្នាំថេរ និងតម្លៃលក់ផ្លែស្វាយ ថេរ ៨០០រៀល/គក្រ និងពុំទាន់គិតបញ្ចូលនូវការចំណាយប្រមូលផលផ្លែស្វាយ រួមជាមួយការដឹកជញ្ជូនផលស្វាយទៅកាន់ទីផ្សារ។

**តារាងចំណូល ចំណាយប្រចាំឆ្នាំលើការដាំស្វាយកែវរមៀតចំនួន ២០៥ ដើម/ហិកតា**

| | **បរិយាយ** | **ឯកតា** | **ចាប់ផ្តើម** | **ឆ្នាំទី១** | **ឆ្នាំទី២** | **ឆ្នាំទី៣** | **ឆ្នាំទី៤** | **ឆ្នាំទី៥** | **ឆ្នាំទី៦** |
|---|---|---|---|---|---|---|---|---|---|
| 1 | ទិន្នផល/ដើម | គក្រ | | | | 30 | 50 | 70 | 90 |
| 2 | ទិន្នផលសរុប | គក្រ | - | - | - | 6,150 | 10,250 | 14,350 | 18,450 |
| 3 | កាត់ខូចខាត10% | គក្រ | - | - | - | 5,535 | 9,225 | 12,915 | 16,605 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 4 | ចំណូលពីការលក់ | លានរ | - | - | - | 4.43 | 7.38 | 10.33 | 13.28 |
| 5 | ចំណាយសរុប | លានរ | 12.96 | 5.33 | 5.33 | 5.33 | 5.33 | 5.33 | 5.33 |
| 6 | ចំណាញ ខាតសរុប | លានរ | (12.96) | (5.33) | (5.33) | (0.90) | 2.05 | 5.00 | 7.95 |

ករណីកសិករមានគំនិតក្នុងការធ្វើពិពិធកម្មកសិកម្ម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយទៅតាមស្ថានភាពទីផ្សារ និងស្ថានភាពតម្រូវការដើម្បីកសាងនូវចង្វាក់តម្លៃដែលមានលក្ខណៈប្រកួតប្រជែង សហគ្រិនកសិករអាចដាំដំណាំរួមផ្សំមួយចំនួននៅតាមចន្លោះដើមស្វាយ ដែលអាចទទួលបាននូវផលិតផលកសិកម្មដែលមានគុណភាពជាប់ជាប្រចាំហើយក្នុងពេលជាមួយគ្នា អាចបង្កើនសមត្ថភាពស្រូបយកនូវប្រាក់ចំណូលបន្ថែម និងសម្រេចស្តង់ដារគុណភាពដែលទីផ្សារត្រូវការ។

## ៩.បញ្ហាប្រឈម

- តម្លៃផ្លែស្វាយកម្ពុជាយើងបច្ចុប្បន្ននេះមានការចុះថោកខ្លាំង ដោយសារមានការប្រកួតប្រជែងជាមួយប្រទេសដទៃដូចជា វៀតណាម ថៃ មីយ៉ាន់ម៉ា ឥណ្ឌា ដែលធ្វើឲ្យផ្លែស្វាយរបស់កម្ពុជាធ្លាក់ថ្លៃ និងមានភាពពិបាកក្នុងការនាំផ្លែស្វាយស្រស់ទៅប្រទេសចិនផងដែរ។ប្រឈមនឹងការប្រកួតប្រជែងទីផ្សារជាមួយប្រទេសជិតខាងដែលនាំចូលទៅទីផ្សារប្រទេសចិនដូចគ្នា។ ទន្ទឹមនេះប្រទេសចិនក៏កំពុងស្ថិតនៅរដូវកាលប្រមូលផលផ្លែស្វាយដូចគ្នា ជាហេតុធ្វើឲ្យមានការប្រកួតប្រជែងតម្លៃទីផ្សារ។
- កសិករមួយចំនួនគាត់ធ្វើការដាំដុះទៅតាមការយល់ឃើញឬដាំតាមយថាកម្ម ដោយមិនបានយកចិត្តទុកដាក់អនុវត្តតាមបច្ចេកទេសឱ្យបានត្រឹមត្រូវ។
- ការចំណាយវិនិយោគលើការដាំដុះ ថែទាំដំណាំស្វាយមានតម្លៃខ្ពស់ និងពិបាកថែទាំ
- ចំពោះការចរចាភូតគាមអនាម័យគឺមានការតឹងតែង ហើយក៏មិនមែនរាល់កសិផលទាំងអស់ត្រូវតែចរចាទីផ្សារនោះទេ។
- ផលិតផលនាំចេញចែកចេញជាពីរ គឺផលិតផលមិនជាប់កម្រិតកំណត់ និងជាប់កម្រិតកំណត់។

-ចំពោះផលិផលមិនជាប់កម្រិតកំណត់ មានន័យថាទំនិញនោះមិនមានហានិភ័យទាក់ទងនឹងអនាម័យ និងភូតគាមអនាម័យខ្ពស់ ដូច្នេះប្រទេសដែលនាំចូលគេមិនតម្រូវឲ្យមានការចរចាវាយតម្លៃហានិភ័យភូតគាមអនាម័យ ប៉ុន្តែមុននឹងនាំចេញកសិផលទាំងនោះ ប្រទេសដែលនាំចេញនេះត្រូវតែធ្វើការវាយតម្លៃត្រួតពិនិត្យ និងចេញលិខិតបញ្ជាក់និងធានានៅចំពោះមុខប្រទេសនាំចូលនោះថាកសិផលទាំងនេះគឺមានសុវត្ថិភាព និងមិននាំចូលនូវសមាសធាតុចង្រៃដែលជាភូតគាមអនាម័យទៅដល់ប្រទេសទាំងនោះ។

-ចំណែកប្រភេទផលិផលទី២ជាប្រភេទទំនិញជាប់កម្រិតកំណត់ គឺជាប្រភេទទំនិញ ឬកសិផលដែលមានហានិភ័យខ្ពស់ ដូច្នេះប្រទេសដែលនាំចូលតែងតែតឹងរឹងលើការដាក់កម្រិតលក្ខខណ្ឌ និងការចរចាភូតគាមអនាម័យទំនិញកសិផល។

- កសិករអះអាងថា ពួកគាត់នៅតែប្រឈមនឹងការលំបាក និងមិនទាន់បានយល់ដឹងច្បាស់នៅឡើយអំពីស្តង់ដារនៃការដាំដុះស្វាយដើម្បីនាំចេញត្រង់ទៅកាន់ទីផ្សារក្រៅប្រទេសដូច្នេះហើយពួកគាត់នៅតែបន្តពឹងផ្អែកលើឈ្មួញកណ្តាល គឺដោយសារតែពួកគាត់នៅមិនទាន់បានចងក្រងជាសហគមន៍ និងមិនមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងក្រុមហ៊ុននាំចេញស្វាយ ដូច្នេះហើយទើបពួកគាត់មិនអាចដាំដុះស្វាយបានត្រឹមត្រូវទៅតាមស្តង់ដារនាំចេញ។

## ១០.ដំណោះស្រាយ

វិធានការមួយចំនួនក្នុងការជួយដោះស្រាយការធ្លាក់ថ្លៃផ្លែស្វាយ មានដូចជា÷

- កសិករត្រូវដាំដុះនិងផលិតផ្លែស្វាយឱ្យមានគុណភាព និងស្តង់ដារស្របតាមភូតគាមអនាម័យ។ បន្ថែមនេះត្រូវមានថ្លៃដើមទាប និងការដឹកជញ្ជូនក៏ត្រូវមានលក្ខណៈប្រកួតប្រជែងទើបកម្ពុជាអាចនាំចូលកសិផលទៅទីផ្សារអន្តរជាតិបានច្រើន។
- ក្រុមហ៊ុនឯកជនដែលមានបំណងនាំស្វាយចេញត្រូវជួយសាងសង់បន្ថែមកន្លែងសម្លាប់មេរោគឱ្យបានច្រើន និងឱ្យមានការវិនិយោគការសាង់សង់កន្លែងពិសោធន៍ផងដែរ។
- វិស័យឯកជនត្រូវជួយបង្កើនរោងចក្រកែច្នៃធ្វើដំណាប់ស្វាយ និងទឹកស៊ីរ៉ូស្វាយឱ្យបានច្រើនដែលនេះជាតម្រូវការខ្ពស់ ហើយទីផ្សារមិនទាន់មានការប្រកួតប្រជែងនិងមិនមានប្រទេសណាផ្គត់ផ្គង់ច្រើន។
- ការផ្សាភ្ជាប់ទំនាក់ទំនងរវាងបណ្តុំកសិករដាំស្វាយ និងក្រុមហ៊ុននាំចេញ នឹងអាចបង្កើនឱកាសដល់កសិករទទួលបាននូវការបណ្តុះបណ្តាលបច្ចេកទេសសម្រាប់ផលិតកម្មស្វាយនាំចេញ និងធានាបាននូវស្ថិរភាពទីផ្សារផងដែរ។
- ប្រជាកសិករដាំស្វាយគួរចងក្រងជាសហគមន៍ ឬជាបណ្តុំដោយសហការជាមួយក្រុមហ៊ុននាំចេញឱ្យបានល្អទើបអាចធ្វើការដាំដុះស្វាយអាចនាំចេញបានខណៈពេលបច្ចុប្បន្នកម្ពុជាមានទីផ្សារនាំចេញស្វាយស្រស់ដោយត្រង់ទៅកាន់ប្រទេសកូរ៉េខាងត្បូង និងប្រទេសចិន ជាមួយនឹងតម្លៃទីផ្សារខ្ពស់ផងដែរ។
- ដាក់ពាក្យស្នើសុំចុះបញ្ជីចំការស្វាយកែវរមៀត និងបញ្ជាក់ទីតាំងវេចខ្ចប់សម្រាប់ការនាំចេញទៅប្រទេសចិន នៅក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ......................

**ពាក្យស្នើសុំចុះបញ្ជីចម្ការស្វាយ និងទីតាំងវេចខ្ចប់សម្រាប់នាំចេញផ្លែស្វាយស្រស់ទៅកាន់ប្រទេសចិន**

ខ្ញុំបាទ □ / នាងខ្ញុំ □ ឈ្មោះ : ........................................................................................................

កាន់អត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែនលេខ : ................................................... ចុះថ្ងៃទី ........... ខែ ........... ឆ្នាំ...........

ជាប្រធានក្រុមហ៊ុន : ........................................................................................................

អាសយដ្ឋានក្រុមហ៊ុន : ........................................................................................................

ទូរស័ព្ទទំនាក់ទំនង : ........................................................................................................

**<u>សូមគោរពជូន</u>**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម**

**<u>កម្មវត្ថុ:</u>** សំណើសុំការត្រួតពិនិត្យវាយតម្លៃដើម្បីទទួលបានការចុះបញ្ជីចម្ការស្វាយ និងទីតាំងវេចខ្ចប់សម្រាប់នាំចេញផ្លែស្វាយស្រស់ទៅកាន់ប្រទេសចិន។

**<u>ឯកសារជូនភ្ជាប់៖</u>**

១. លិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្ម ដែលកំណត់ពីកម្មវត្ថុអាជីវកម្ម □ លេខ............ ចុះថ្ងៃទី........./............/..........

២. វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម □ លេខ........... ចុះថ្ងៃទី........./.........../............

លេខអត្តសញ្ញាណកម្មសារពើពន្ធ (VAT) □ លេខ........... ចុះថ្ងៃទី........./.........../............

៣. ប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ (ស្ថិតក្នុងសុពលភាព) □ លេខ........... ចុះថ្ងៃទី........./.........../............

៤. ប្លង់កម្មសិទ្ធកាន់កាប់ដីចម្ការ □ លេខ........... ចុះថ្ងៃទី........./.........../............

៥. ឯកសារបច្ចេកទេសរបស់ក្រុមហ៊ុនស្តីពីការគ្រប់គ្រងចម្ការស្វាយ

៦. លិខិតផ្លូវការដទៃដែលពាក់ព័ន្ធ (ប្រសិនបើមាន)៖ □ ..............................................................
..............................................................

(បណ្តាឯកសារពាក់ព័ន្ធដទៃទៀត ដែលមានប្រសិទ្ធភាពគាំទ្រការវាយតម្លៃ និងប្រគល់ជូនបន្ថែមតាមការចាំបាច់)

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពអនុញ្ញាតជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា ក្នុងគោលបំណងចូលរួមចំណែកជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារប្រទេសចិន ក្រុមហ៊ុនយើងខ្ញុំបានធ្វើការដាំដុះដំណាំស្វាយ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រការនាំចេញផ្លែស្វាយស្រស់ទៅកាន់ប្រទេសចិន។

ដើម្បីត្រៀមលក្ខណៈការចុះត្រួតពិនិត្យ វាយតម្លៃពីអគ្គរដ្ឋបាលគយចិន ក្រុមហ៊ុនយើងខ្ញុំគោរពស្នើសុំមន្ត្រីជំនាញពីនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ចុះត្រួតពិនិត្យ និងផ្តល់ដំបូន្មានសម្រាប់ធ្វើការលម្អ (ក្នុងករណីមិនទាន់សមស្របតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យ) ឱ្យបានមុនការមកដល់របស់មន្ត្រីនៃអគ្គរដ្ឋបាលគយចិន។

សូម**ឯកឧត្តមប្រតិភូ**មេត្តាពិនិត្យ និងសម្រេចធ្វើការពិនិត្យវាយតម្លៃក្រុមហ៊ុនយើងខ្ញុំ ដើម្បីទទួលបានការចុះបញ្ជីចម្ការស្វាយដើម្បីនាំចេញផ្លែស្វាយស្រស់ទៅកាន់ប្រទេសចិន ដោយអនុគ្រោះ។

ក្រុមហ៊ុនយើងខ្ញុំ នឹងទទួលការសហការ និងគាំទ្រសកម្មភាពចុះត្រួតពិនិត្យវាយតម្លៃរបស់អគ្គនាយកដ្ឋានកសិកម្ម។

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ............... ឆ្នាំ..................

ហត្ថលេខា និងត្រាក្រុមហ៊ុន

## ១១. សន្និដ្ឋានសរុបលើវិស័យដំណាំហូបផ្លែ ÷

ដោយដំណាំដើមឈើហូបផ្លែក្នុងស្រុកដែលមានសក្តានុពលលើទីផ្សារ រាជរដ្ឋាភិបាលបាននិងកំពុងត្រៀមរៀបចំដាក់ចេញនូវគោលនយោបាយមួយចំនួនដូចជា ÷

- រៀបចំផែនការ និងទិសដៅពង្រីកការដាំដំណាំឈើហូបផ្លែ ដែលមានសក្តានុពលសម្រាប់ទីផ្សារក្នុង និងក្រៅប្រទេស។
- បង្កើតស្ថានីយបង្កាត់ និងផលិតពូជដំណាំហូបផ្លែដែលពេញនិយមសម្រាប់ផ្គត់ផ្គង់ដល់កសិករដើម្បីងាយស្រួលដាក់លក់នៅលើផ្សារក្នុង និងក្រៅប្រទេស។
- អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដើម្បីជួយសម្រួលដល់ខ្សែច្រវាក់ផលិតកម្មដំណាំហូបផ្លែ
- បណ្តុះបណ្តាលបច្ចេកទេសដាំដុះទំនើប រួមទាំងបច្ចេកទេសមុននិងក្រោយប្រមូលផលដល់អ្នកដាំដុះឱ្យស្របតាមស្តង់ដារសុវត្ថិភាព ឆ្លើយតបនឹងលក្ខខណ្ឌតម្រូវសម្រាប់ការនាំចេញ។
- ចងក្រងសហគមន៍ផលិតដំណាំហូបផ្លែដើម្បីជំរុញផលិតកម្មស្របតាមស្តង់ដារនិងតម្រូវការទីផ្សារ។
- លើកទឹកចិត្តដល់វិស័យឯកជនក្នុងការបង្កើតការវិនិយោគ ដើម្បីជំរុញខ្សែច្រវាក់ផលិតកម្ម និងការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងជំរុញការនាំចេញទៅក្រៅប្រទេស ជាពិសេសការប្រើប្រាស់ទុនឥណទានពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មដែលជាធនាគាររដ្ឋបម្រើគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យកសិកម្ម។
- គួររៀបចំបង្កើតសហព័ន្ធកសិឧស្សាហកម្មកម្ពុជាដើម្បីគាំទ្រ លើកទឹកចិត្ត និងជំរុញការអភិវឌ្ឍវិស័យកសិកម្ម កសិឧស្សាហកម្ម និងកសិធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។